**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
## ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រី
## ក្រសួងមុខងារសាធារណៈ

## ក្នុងពិធីបើក
## សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ គ.ជ.អ.ប

**រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩**

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវតំណាងក្រសួង ស្ថាប័ននានា**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល**
- **ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមកចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់គ.ជ.អ.ប នាពេលនេះ។ ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីអញ្ជើញចូលរួមសិក្ខាសាលាជាតិដែលនឹងប្រព្រឹត្តទៅរយៈពេញមួយថ្ងៃនេះ។

ដូចសព្វមួយដងជារៀងរាល់ចុងឆ្នាំនីមួយៗ គ.ជ.អ.បតែងតែរៀបចំឲ្យមានពិធីជួបជុំគ្នារវាងអ្នកពាក់ព័ន្ធនានាទាំងស្ថាប័ននៅថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ ទាំងក្នុងក្របខណ្ឌអ្នកធ្វើគោលនយោបាយ អ្នកគាំទ្រ តាមដានត្រួតពិនិត្យ និងទាំងក្នុងក្របខណ្ឌអ្នកប្រតិបត្តិផ្ទាល់ដែលមកពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលក្នុងសិក្ខាសាលាជាតិប្រចាំឆ្នាំ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្ត

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ របស់គ.ជ.អ.ប និងផ្តល់ឱកាសឱ្យមានការពិភាក្សា ពិគ្រោះយោបល់គ្នាដើម្បីរិះរកដំណោះស្រាយ និងស្វែងរកការឯកភាពគ្នាលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់គ.ជ.អ.ប។

ផ្អែកតាមកម្មវិធីដែលបានគ្រោងទុកសម្រាប់រយៈពេលពេញ១ថ្ងៃនេះ អង្គសិក្ខាសាលាជាតិរបស់យើងនឹងមានរបៀបវារៈសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវឌ្ឍនភាពនិងបញ្ហាប្រឈមនានាដែលបានអនុវត្តក្នុងឆ្នាំ២០១៩ របស់គ.ជ.អ.ប សេចក្តីព្រាងសកម្មភាពជាអាទិភាពនានាដែលគ្រោងនឹងសម្រេចឱ្យបាននៅក្នុងឆ្នាំ២០២០របស់គ.ជ.អ.ប និងលេខាធិការដ្ឋានគ.ជ.អ.ប ការវិភាជន៍ថវិកាជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២០ ការចូលរួមបដិភាគរបស់អង្គការសង្គមស៊ីវិលក្នុងសកម្មភាពកំណែទម្រង់ស្នូល និងវេទិកាសំណួរ ចម្លើយជាមួយវាគ្មិនសំខាន់ៗដែលមកពីក្រសួង ស្ថាប័នមួយចំនួន។ ក្នុងកម្មវិធីបិទនាវសៀលនេះ អង្គសិក្ខាសាលានឹងបានស្តាប់នូវសារនយោបាយនិងគោលការណ៍ណែនាំជាគន្លឹះពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.អ.ប** ដែលនឹងអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសិក្ខាសាលានេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ឆ្នាំ២០២០ខាងមុខនេះ គឺជាឆ្នាំទី២នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនៃនីតិកាលទី៦នៃរដ្ឋសភា ជាឆ្នាំចុងក្រោយនៃផែនការអនុវត្តដំណាក់កាលទី៣របស់គ.ជ.អ.ប និងជាឆ្នាំចុងក្រោយនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០២០) ហើយក៏ជាឆ្នាំដែលគ.ជ.អ.បត្រូវគិតគូរអំពីការរៀបចំកម្មវិធីជាតិសម្រាប់ការអនុវត្តដំណាក់កាលបន្ទាប់ផងដែរ។ អាស្រ័យហេតុនេះ ការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២០ របស់គ.ជ.អ.ប ត្រូវបានគិតគូរប្រមូលផ្តុំនូវបញ្ហាជាអាទិភាពនានាដែលបានកំណត់ក្នុងកម្មវិធីជាតិ១០ឆ្នាំ ហើយដែលយើងមិនទាន់អាចសម្រេចបានក្នុងបណ្តាឆ្នាំកន្លងមក ជាមួយនឹងបញ្ហាជាអាទិភាពនានាដែលគ្រោងសម្រេចឲ្យបាននាឆ្នាំចុងក្រោយនៃកម្មវិធីជាតិនេះដោយផ្អែកលើមូលដ្ឋាននៃកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០១៩-២០២៣) ព្រមទាំងផ្អែកលើមូលដ្ឋាននៃការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គម។

សកម្មភាពជាអាទិភាពនានាដែលត្រូវបានគ្រោងក្នុងសេចក្តីព្រាងបឋមនៃផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២០ របស់គ.ជ.អ.ប ដែលនឹងត្រូវយកមកពិនិត្យ និងពិភាក្សាគ្នាក្នុងសិក្ខាសាលានេះ ក៏មានការជជែកពិភាក្សាគ្នាជាបឋមជាមួយក្រុមការងារតំណាងក្រសួង ស្ថាប័នអនុវត្តនានានាពេលកន្លងមកហើយដែរ។ សេចក្តីព្រាងបឋមនៃផែនការសកម្មភាពនិងថវិកាឆ្នាំ២០២០នេះ បានរៀបចំឡើងដោយផ្អែកទៅលើគម្រោងថវិកាសរុបប្រមាណជាង **៣,៥ទ្រីលានរៀល** ឬមានចំនួនប្រមាណជិត **៩០០ លានដុល្លារអាមេរិក** ដែលក្នុងនោះថវិការដ្ឋប្រមាណជិត **៩៥%** និងថវិកាចូលរួមចំណែកពីដៃគូ

អភិវឌ្ឍន៍ប្រមាណជាង **៥%**។ ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានចំនួនប្រមាណជាង **៣,៤ ទ្រីលានរៀល** ឬមានចំនួនប្រមាណជាង**៨៥៥លានដុល្លារអាមេរិក**។ បើប្រៀបធៀបនឹងឆ្នាំ២០១៩ ថវិការបស់រដ្ឋបាល ថ្នាក់ក្រោមជាតិឆ្នាំ២០២០ខាងមុខនេះ មានចំនួនកើនឡើងប្រមាណជិត **១,១ទ្រីលានរៀល** ឬ មានចំនួនប្រមាណជាង**២៧៦លានដុល្លារអាមេរិក** ដោយសារការបង្កើនអត្រាចូលរួមពីថវិការដ្ឋទៅក្នុងមូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងការបង្កើតឱ្យមាននូវប្រភពចំណូលផ្សេងៗទៀតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំនួនថវិកានេះនៅពុំទាន់បានគិតបញ្ចូលនូវថវិកាដែលត្រូវផ្ទេរសម្រាប់អនុវត្តមុខងារនានា ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសមុខងារដែលត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌស្របនឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងមុខងារក្នុងវិស័យសុខាភិបាលដែលត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលរាជធានី ខេត្ត តាមរយៈអនុក្រឹត្យដែលបានដាក់ចេញនាពេលថ្មីៗនេះ។

ក្នុងនាម គ.ជ.អ.ប ក្នុងនាមគណៈកម្មាធិការកំណែទម្រង់រដ្ឋបាលសាធារណៈ និងក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមធ្វើការកត់សំគាល់ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចូលរួមចំណែក ក្នុងការសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនក្នុងអាណត្តិទី៥ និងដើមអាណត្តិទី៦នៃរាជរដ្ឋាភិបាល ពិសេសក្នុងឆ្នាំ២០១៩នេះពាក់ព័ន្ធទៅនឹងការអនុវត្តកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលជា អាទិ៍គឺៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់តាមវិស័យនានា។ ដើម្បីធានាសម្រេចបាននូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល កម្មវិធីកំណែទម្រង់ដ៏សំខាន់ទាំងនេះនឹងត្រូវបង្កើនល្បឿនឲ្យបានខ្លាំងក្លា ស្របគ្នា គាំទ្រនិងសហការគ្នាមានសង្គតិភាពជាមួយគ្នា និងឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ស្របតាមគោលការណ៍តម្រង់ទិសក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដែលតម្រូវឲ្យសកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍទាំងអស់ ត្រូវចេះសម្របសម្រួលគ្នាបានជាប្រព័ន្ធតួអង្គតែមួយ ដោយមិនត្រឹមតែបំពេញតួនាទីរៀងៗខ្លួនដោយមិនចោទប្រកាន់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្របសម្រួល និងសហការគ្នាយ៉ាងជិតស្និទដើម្បីសម្រេចនូវបេសកកម្ម គោលបំណង គោលនយោបាយរបស់រាជរដ្ឋាភិបាល និងឆ្លើយតបទៅនឹងកង្វល់ ឬសំណូមពររបស់ប្រជាជនប្រកបដោយប្រសិទ្ធភាព។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គសិក្ខាសាលាជាតិអំពីការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈដូចខាងក្រោមៈ

កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ជាកម្មវិធីកំណែទម្រង់មួយ ក្នុងចំណោមកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលដែលបានចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០០០ ដែលបានចូលរួមចំណែកជាមួយកម្មវិធីកំណែទម្រង់ផ្សេងៗទៀតដើម្បីអនុវត្តឲ្យបានសម្រេចនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ

ចតុកោណរបស់រាជរដ្ឋាភិបាល ជាពិសេសការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច ដើម្បីសម្រេចឲ្យបាននូវគោលដៅយុទ្ធសាស្ត្រសម្រាប់ ***កំណើន ការងារ សមធម៌*** និង***ប្រសិទ្ធភាព***។ គិតមកទល់ពេលនេះ យើងទើបតែបានបញ្ចប់នូវការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈពីឆ្នាំ២០១៤-២០១៨ ជាមួយនឹងសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការកែលំអរគុណភាពសេវាសាធារណៈ ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ការកែទម្រង់ប្រព័ន្ធបៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗ ការតាមដាន ការត្រួតពិនិត្យនិងវាយតម្លៃ និងការផ្សារភ្ជាប់ការងារកំណែទម្រង់មានលក្ខណៈអន្តរវិស័យ ព្រមជាមួយនឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងបណ្តាប្រទេសជាសមាជិកអាស៊ាន។

ទន្ទឹមនឹងសមិទ្ធផលខាងលើនេះ យើងនៅមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវដោះស្រាយជាបន្ទាន់ និងជាអាទិភាពនៅពេលដ៏ខ្លីខាងមុខតាមរយៈការដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រដែលផ្តោតលើការប្រមូលផ្តុំសមិទ្ធផលតូចៗបញ្ចូលគ្នា ដើម្បីប្រែក្លាយឲ្យលេចជារូបភាពធំជាងមុន និងជាក់ស្តែងនិយម ការគិតគូរអំពីការដំឡើងប្រាក់បៀវត្សដើម្បីស្រូបយកអ្នកមានទេពកោសល្យ សមត្ថភាព ជំនាញវិជ្ជាជីវៈដើម្បីជំរុញនិងលើកកម្ពស់ផលិតភាពនិងសមត្ថភាពរបស់ស្ថាប័នសាធារណៈ ការកែទម្រង់មុខងារសាធារណៈឆ្ពោះទៅរកប្រព័ន្ធនិយោជន៍ដោយសំដៅទៅលើអភិក្រមផ្អែកលើលទ្ធផល និងការជំរុញការកែទម្រង់រដ្ឋបាលសាធារណៈឲ្យមានប្រសិទ្ធភាពជាងមុន និងបង្កើនល្បឿនជាងមុន។

ឆ្នាំ២០១៩នេះ គឺជាឆ្នាំចាប់ផ្តើមនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដែលមានរយៈពេល១២ឆ្នាំ(២០១៩-២០៣០)ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងបង្គោលចរឆ្នាំ២០៣០ ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ កម្មវិធីជាតិនេះ បានកំណត់នូវចក្ខុវិស័យដ៏ច្បាស់លាស់មួយគឺ **ការធានាឲ្យបាននូវរដ្ឋបាលសាធារណៈផ្តោតលើប្រជាជនជាស្នូលដែលមានលក្ខណៈខ្លាំង ស្អាតស្អំ និងឆ្លាតវៃ។** រដ្ឋបាលត្រូវដាក់ប្រជាជនជាស្នូលនៃការផ្តល់សេវាសាធារណៈ និងឈរលើព្រហ្មវិហារធម៌ដោយមានការចូលរួមពីប្រជាជនក្នុងគ្រប់ដំណាក់កាលនៃការរៀបចំ ការអភិវឌ្ឍ ការផ្តល់ព័ត៌មានត្រលប់ និងការត្រួតពិនិត្យនិងវាយតម្លៃ។ រដ្ឋបាលសាធារណៈត្រូវតែខ្លាំង មានសមត្ថភាពរឹងមាំ មានវិជ្ជាជីវៈ នវានុវត្តន៍ និងអាចបត់បែនឆ្លើយតបប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព។ មន្ត្រីត្រូវប្រកាន់យកគោលការណ៍សុចរិតធម៌ បំពេញការងារដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវឈរលើអភិក្រម **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**។ រដ្ឋបាលសាធារណៈប្រើប្រាស់នវានុវត្តន៍ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងបច្ចេកទេសទាន់សម័យប្រកបដោយភាពវៃឆ្លាត ក្នុងការផ្តល់សេវាឲ្យកាន់តែមានប្រសិទ្ធភាព និងប្រសើរជាលំដាប់។

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ យើងនឹងប្រើប្រាស់នូវយុទ្ធសាស្ត្រចំនួន៣ គឺ៖ **ទី១**៖ ការជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងរដ្ឋបាលសាធារណៈ **ទី២**៖ ការជំរុញនិងការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និង**ទី៣**៖ ការផ្សារភ្ជាប់សកម្មភាពកំណែទម្រង់

រដ្ឋបាលសាធារណៈជាមួយនឹងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ កម្មវិធីជាតិនេះ នឹងត្រូវដាក់ឲ្យអនុវត្តជាបីដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទី១(២០១៩-២០២៣)៖ ជាដំណាក់កាលការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ** ដោយផ្តោតលើការកែទម្រង់និងការលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ។

**ដំណាក់កាលទី២ (២០២៣-២០២៧) ជាដំណាក់កាលនៃការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ**ដោយផ្តោតលើការបន្តពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការដាក់ឲ្យអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម។

**ដំណាក់កាលទី៣ (២០២៧-២០៣០) ជាដំណាក់កាលនៃការលើកកម្ពស់គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ** ដោយផ្តោតទៅលើការបន្តអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការផ្តល់សេវាសាធារណៈប្រកបដោយឧត្តមភាព និងការត្រួតពិនិត្យវាយតម្លៃគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!***

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះការបន្តគាំទ្រទាំងជំនួយផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍នានាដល់ការអភិវឌ្ឍន៍លើគ្រប់វិស័យ និងកិច្ចដំណើរការកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល។ ខ្ញុំក៏សូមអរគុណដល់ការចូលរួមចំណែកក្នុងភាពជាដៃគូដ៏សំខាន់ និងប្រកបដោយលក្ខណៈស្ថាបនារបស់អង្គការសង្គមស៊ីវិលនានានៅក្នុងការបំពេញការងាររបស់រាជរដ្ឋាភិបាលផងដែរ។

មុននឹងបញ្ចប់ ក្នុងនាមគ.ជ.អ.ប ខ្ញុំសូមសម្តែងនូវជំនឿជឿជាក់យ៉ាងមុតមាំលើការចូលរួមផ្តល់យោបល់ដ៏មានតម្លៃរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នៅក្នុងការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់គ.ជ.អ.ប ហើយខ្ញុំសង្ឃឹមថា សិក្ខាសាលាជាតិនេះនឹងទទួលបានលទ្ធផលជាផ្លែផ្កាតាមគោលបំណងដែលបានគ្រោងទុក។

ជាមួយគ្នានេះ ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរជូនចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ វិបុលភាព និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចរបស់ខ្លួន។ *ខ្ញុំសូមប្រកាសបើក**សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់គ.ជ.អ.ប** ចាប់ពីពេលនេះតទៅ។*

**សូមអរគុណ** !